**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ**

**លេខ** :............០០៤/២០..................**ក.ប**/ស.ណ.ន.ខ.ល

# សេចក្ដីណែនាំ

## ស្ដីពី

## ការអនុវត្តវិធានការបង្ការជំងឺរលាកសួតដោយវីរុសកូរ៉ូណាថ្មី (2019-nCoV) នៅតាមរោងចក្រ សហគ្រាស គ្រឹះស្ថាន

ក្នុងគោលបំណងដើម្បីចូលរួមចំណែកក្នុងការបង្ការ និងទប់ស្កាត់វីរុសកូរ៉ូណាថ្មី (2019-nCoV) ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ សូមធ្វើការណែនាំដល់ម្ចាស់ ឬនាយករោងចក្រ សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតទាំងអស់ ត្រូវអនុវត្តនូវវិធានការដូចខាងក្រោម៖

១. និយោជក កម្មករនិយោជិត ដែលធ្វើដំណើរមកពីតំបន់ ដែលមានការរាតត្បាតនៃវីរុសកូរ៉ូណាថ្មី (2019-nCoV) និងមានប្រវត្តិធ្វើដំណើរពីប្រទេសចិន ដែលមានរោគសញ្ញាមួយចំនួន ដូចជាការឡើងកំដៅខ្លួនចាប់ពី ៣៨អង្សាសេ ក្អក ហៀរសំបោរ ឈឺបំពង់ក ដង្ហើមខ្លី ឬពិបាកដកដង្ហើម ត្រូវធ្វើការត្រួតពិនិត្យ និងតាមដានក្នុងរយៈពេល ១៤ថ្ងៃ នៅតាមសេវាសុខាភិបាល ដែលនៅជិត ឬទូរស័ព្ទមកលេខ ១១៥។

២. ប្រសិនបើមាន និយោជក កម្មករនិយោជិតដែលមានអាការដូចជាគ្រុនក្ដៅ ក្អក កណ្ដាស់ ផ្ដាសាយ ហៀរសំបោរ ឬឈឺបំពង់ក ត្រូវបញ្ជូនទៅរកសេវាព្យាបាល ឱ្យបានទាន់ពេលវេលា ឬទូរស័ព្ទមកលេខ ១១៥។

៣. ត្រូវដាស់តឿន និងរំលឹកជាប្រចាំ ដល់កម្មករនិយោជិតឲ្យពាក់ម៉ាស់ការពារទាំងក្នុង និងក្រៅកន្លែងធ្វើការ ដូចជាប្រភេទ៖ ម៉ាស់វេជ្ជសាស្ត្រ (Medical Mask)

៤. ចៀសវាងប៉ះពាល់អ្នកមានជំងឺផ្លូវដង្ហើមស្រួចស្រាល់ ដែលមានអាការដូចជាគ្រុនក្ដៅ ក្អក និង កណ្ដាស់ ឬផ្ដាសាយ និងត្រូវរក្សាចម្ងាយច្រើនជាងមួយម៉ែត្រពីបុគ្គលដែលមានរោគសញ្ញាទាំងនេះ។

៥. ចៀសវាងទៅទីផ្សារលក់សត្វរស់ ឬទៅកសិដ្ឋានចិញ្ចឹមសត្វ ឬប៉ះពាល់សត្វព្រៃ ឬទៅកន្លែងដែលសង្ស័យថាមានមេរោគឆ្លង។

៦. ចៀសវាងការខាកស្ដោះក្នុងកន្លែងធ្វើការទីធ្លាសហគ្រាស គ្រឹះស្ថាន និងទីសាធារណៈ។

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

៧. ចៀសវាងការប៉ះពាល់ភ្នែក ច្រមុះ មាត់ បន្ទាប់ពីប៉ះពាល់សត្វ និងផលិតផលសត្វ សត្វឈឺ សាច់ខូចគុណភាព កាកសំណល់សត្វ ទឹកសរីរៈសត្វ និងវត្ថុប្រើប្រាស់ក្នុងផ្សារ ឬវត្ថុប្រើប្រាស់ផ្សេងៗរបស់អ្នកជំងឺផ្លូវដង្ហើម។

៨. ត្រូវលាងដៃឱ្យបានទៀងទាត់ និងញឹកញាប់ជាមួយសាប៊ូ និងទឹកស្អាត ឬទឹកអាល់កុល បន្ទាប់ពីប៉ះពាល់ផ្ទាល់ជាមួយអ្នកមានអាការដូចជា គ្រុនក្តៅ ក្អក និងកណ្តាស់ ឬផ្តាសាយ ឬវត្ថុផ្សេងៗ ដែលអាចជាប្រភពមេរោគ ឬនៅពេលឃើញដៃកខ្វក់ ឬប្រឡាក់ ឬក្រោយពីប៉ះពាល់សត្វ និងត្រូវលាងសម្អាតដៃភ្លាមជាមួយសាប៊ូ និងទឹកស្អាត ឬទឹកអាល់កុល ក្រោយពីក្អក ឬកណ្តាស់។ ត្រូវលាងដៃបន្ទាប់ពីមានប៉ះជាមួយសំបោរ ឬទឹករំអិលពីផ្លូវដកដង្ហើម។

៩. ប្រកាន់ខ្ជាប់នូវការអនុវត្តអនាម័យស្អាត សុវត្ថិភាពចំណីអាហារ ដោយបរិភោគអាហារដែលឆ្អិនល្អ ពិសេសសាច់ និងស៊ុត។ ចំពោះអ្នកចម្អិនអាហារត្រូវប្រើប្រាស់ជ្រុញ និងកាំបិតផ្សេងគ្នាសម្រាប់អាហារឆៅ និងអាហារឆ្អិន និងលាងដៃនៅចន្លោះពេលចាប់កាន់អាហារឆៅ និងអាហារឆ្អិន។

១០. អ្នកមានអាការក្អក ឬកណ្តាស់ ត្រូវខ្ទប់មាត់ និងច្រមុះ ដោយប្រើកន្សែង ក្រមា ក្រដាស ឬយ៉ាងហោចណាស់ត្រូវប្រើគន្លាក់កែងដៃជំនួសបាតដៃ។

១១. ត្រូវបន្តអប់រំ និងផ្សព្វផ្សាយដល់កម្មករនិយោជិតអំពីវិធានបង្ការការពារ និងសារអប់រំសុខភាពស្តីពីការពារជំងឺរលាកសួតដោយវីរុសកូរ៉ូណាថ្មី ដែលចេញដោយក្រសួងសុខាភិបាល ឬរៀងរាល់ពេលដែលក្រសួងសុខាភិបាលចេញសេចក្តីណែនាំថ្មីអំពីវិធានបង្ការការពារ និងទប់ស្កាត់។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានក្តីសង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ ឬនាយករោងចក្រ សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតទាំងអស់នឹងអនុវត្តតាមខ្លឹមសារសេចក្តីណែនាំនេះអោយបានត្រឹមត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃ អង្គារ ៤កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូនៈ**

-រដ្ឋបាលរាជធានី-ខេត្ត "ដើម្បីជូនជ្រាប"

-គ្រប់អង្គភាពក្រោមឱវាទ

-មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត

-សហជីព និងសមាគមនិយោជកគ្រប់លំដាប់ថ្នាក់ "ដើម្បីអនុវត្ត"

-ឯកសារ កាលប្បវត្តិ